# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៩១០
ចុះថ្ងៃទី ១១_១០_២០១១
សាលដីកា
លេខ : ៤៦ "ក្រ.III.ស"
ចុះថ្ងៃទី ១១_០៧_២០១២

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៨_០៦_២០១២ ដោយមានសមាសភាពដូចខាងក្រោម:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៩១០ ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១១ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] **វណ្ណារិទ្ធ** ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ មុខរបរគ្មាន កើតនៅភូមិធ្នក ឃុំធ្នក ស្រុកទ្រាំង ខេត្តតាកែវ ទី[redacted] ក្រុម១០៥ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់ ទោសពីមុនគ្មាន ដីកាចាប់ខ្លួន ចុះថ្ងៃទី ២៤-១០-២០០៨, ឃុំខ្លួនថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១១។

មានលោក [redacted] **ចន្ថា** ជាមេធាវីការពារ។

**<u>ជាប់ចោទពីបទ:</u> ប្លន់ (លួចមានគ្រឿងដៃ)** ប្រព្រឹត្តនៅផ្ទះលេខ ៦៧E ផ្លូវរថភ្លើង សង្កាត់ស្រះចក ខណ្ឌដូនពេញ ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ច័ន្ទសីហ:** ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៦៧ ផ្លូវរថភ្លើង ក្រុមម២៣ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។៚

## ៦ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៨ វេលាម៉ោង ២៣:៣០នាទី នៅចំណុចផ្ទះលេខ ៦៧E ផ្លូវរថភ្លើង ក្រុមម២៣ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឈ្មោះ [redacted] សុផាត និងឈ្មោះ រិទ្ធិ បានធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] ច័ន្ទសីហៈ ដោយប្រើដែករាងអក្សរតេកាច់បំបែកគ្រាប់សោរ ។ ពេលលួចបានម៉ូតូហើយ ស្អែកឡើងអ្នកទាំងពីរបានជិះម៉ូតូដែលលួចបានទៅជួបឈ្មោះ [redacted] ពៅ នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ដើម្បីយកម៉ូតូនេះឱ្យឈ្មោះ [redacted] ពៅ ទៅបញ្ចាំ។ ដោយឈ្មោះនេះ គ្មានអត្តសញ្ញាណប័ណ្ណ សម្រាប់បញ្ចាំម៉ូតូ ឈ្មោះ [redacted] ពៅ បានយកអត្តសញ្ញាណប័ណ្ណរបស់ប្អូនឈ្មោះ [redacted] ចាន់ម៉ុល ដើម្បីដាក់បញ្ចាំម៉ូតូ ពេលនោះឈ្មោះ [redacted] ចាន់ម៉ុល ដែលជាប្អូនមកដល់ ក៏បានរួមដំណើរដោយជិះម៉ូតូមានគ្នា ៣នាក់ ទៅបញ្ចាំម៉ូតូនៅម្តុំឃ្លាំងរំសេវ ក៏ត្រូវសមត្ថកិច្ចសាកសួរ និងឃាត់ខ្លួន ចំណែកឈ្មោះ រិទ្ធិ ដែលនៅរងចាំនៅផ្ទះរបស់ឈ្មោះ [redacted] ចាន់ម៉ុល បានរត់គេចខ្លួនបាត់ ។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៧ កប៤ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- កែប្រែបទចោទ និងកន្លែងប្រព្រឹត្តបទល្មើសលើឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ ២៦ឆ្នាំ និងឈ្មោះ [redacted] ចាន់ម៉ុល ហៅ ទូច ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ ពីបទ **សមគំនិតក្នុងអំពើប្លន់** ប្រព្រឹត្តនៅសង្កាត់ទន្លេបាសាក់ ខណ្ឌដូនពេញ ទៅបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅផ្ទះលេខ ៦៧ ផ្លូវរថភ្លើង ក្រុម២៣ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូន ពេញ រាជធានីភ្នំពេញ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- ផ្តន្ទាទោស:

ក- ឈ្មោះ [redacted] សុផាត ហៅ ថា ហៅ ស្និត ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ១៣-០៨-២០០៨។

ខ- ឈ្មោះ [redacted] វណ្ណារិទ្ធ ហៅ រិទ្ធ ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន។

ពីបទ: **ប្លន់ (លួចម៉ូតូមានគ្នាច្រើន)** ប្រព្រឹត្តនៅផ្ទះលេខ ៦៧ ផ្លូវរថភ្លើង ក្រុម ២៣ ភូមិ ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៨ វេលាម៉ោង ២៣ និង ២០នាទី តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣- ផ្តន្ទាទោស:

ក- ឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ

ខ- ឈ្មោះ [redacted] ចាន់ម៉ុល ហៅ ទូច ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗ ០១ឆ្នាំ (មួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ១៣-០៨-២០០៨ ពីបទ: **ទទួលផល**

**ចោរកម្ម** ប្រព្រឹត្តនៅផ្ទះលេខ ៦៧ ផ្លូវរថភ្លើង ក្រុម ២៣ ភូមិ ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៨ វេលាម៉ោង ២៣ និង ២០នាទី តាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤- វត្ថុតាងមាន ម៉ូតូ មួយគ្រឿង ម៉ាក Honda ពណ៌ក្រហម ស៊េរី២០០៣ ពាក់ផ្លាក់លេខ កណ ១A ១៥២៦ លេខតួ និងលេខម៉ាស៊ីន ME ៨០២២៩៧៤ ត្រូវប្រគល់ឱ្យឈ្មោះ [redacted] **ច័ន្ទសីហៈ** ជាម្ចាស់វិញ តាមកំណត់ហេតុប្រគល់សំភារៈ ចុះថ្ងៃទី ១១-០៨-២០០៨ របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក ។

៥- សាលក្រមនេះជំនុំជម្រះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍

ក្នុងកំណត់ច្បាប់ ។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] **វណ្ណារិទ្ធ** ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៧ កប៤ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ២ ខ នៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## <u>នាពេលសវនាការ</u>

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ច័ន្ទសីហៈ** បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ ។

ជនជាប់ចោទឈ្មោះ [redacted] **វណ្ណារិទ្ធ** ឆ្លើយថាៈ ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដោយសារតុលាការបានចោទប្រកាន់ថាខ្លួនលួច ខ្លួនមិនបានលួចគេទេ ហើយខ្លួនក៏មិនដឹងថា អ្នកណាជាអ្នកលួចដែរ ខ្លួនបានជួបឈ្មោះ **ផាត** នៅម្តុំផ្លូវរថភ្លើង ម៉ោងប្រហែល ៥-៦ល្ងាច ដោយចៃដន្យ ឈ្មោះ **ផាត** ជិះម៉ូតូម៉ាកសង់ហុងដា ហើយគាត់ហៅខ្លួនឱ្យជិះសំដៅទៅប៊ូឌីងរួចឡើងទៅហៅមិត្តភក្តិពីរនាក់ទៀតសុទ្ធតែមានអត្តសញ្ញាណប័ណ្ណ ចំណែកខ្លួនគ្មានអត្តសញ្ញាណប័ណ្ណទេ ។ ខ្លួនស្គាល់ឈ្មោះ **ផាត** ប្រហែល ៥-៦ខែ ហើយ ខ្លួនអត់បានដើរលេង ឬស៊ីផឹកជាមួយឈ្មោះ **ផាត** ទេ ។ ខ្លួនមិនបានធ្វើសកម្មភាពជាមួយឈ្មោះ **ផាត** ទេ ហើយខ្លួនក៏គ្មានដែកអក្សរ T ដែរ ខ្លួនមិនបានហៅឈ្មោះ **ផាត** ទេ ខ្លួនឡើងមកផ្លូវខ្លួនអត់ដឹងថា ឈ្មោះ **ផាត** គាត់យកម៉ូតូដែលជិះមកពីណាទេ ហើយក៏មិនដឹងថា គាត់លួចម៉ូតូគេដែរ ។ ខ្លួនមិនដែលបានទទួលដីកាពីតុលាការទេ គឺគ្រាន់តែធ្លាប់បានទទួលដីកាពីប៉ុស្តិ៍ ពេលខ្លួនចូលទៅ គេចាប់ខ្លួនតែម្តង ដោយហៅខ្លួនថា ដើម្បីស្រង់ស្ថិតិអ្នកមានភ្លើងឆេះផ្ទះ ។ ខ្លួនជិះម៉ូតូជាមួយឈ្មោះ **ផាត** ទៅប៊ូឌីង ហើយឈ្មោះ **ផាត** បានចេញទៅជាមួយមិត្តភក្តិពីរនាក់ទៀត ដោយខ្លួនមិនបានទៅជាមួយគេទេ ។ ពេលឈ្មោះ **ផាត** ហៅខ្លួនជិះម៉ូតូ ខ្លួននៅផ្លូវជាតិជិតក្លោងទ្វារ

វត្តនាគវ័ន្ត ព្រោះផ្ទះបងធម៌ខ្លួននៅ ជិតវត្តនាគវ័ន្ត។ សំណូមពរ សុំតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង និងសុំដោះលែងខ្លួនឱ្យមានសេរីភាព។

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**

ក្នុងនាមជាតំណាងមហាអយ្យការសាលាឧទ្ធរណ៍ សុំតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៧ កប៤ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ទោះបីជាមានការបដិសេធនៅសវនាការក៏ដោយ ក៏សុំឱ្យក្រុមប្រឹក្សាពិចារណាលើទោសរបស់ជនជាប់ចោទ។ ពិតជាមានអំពើប្លន់ពិតមែន តែជនជាប់ចោទបានបដិសេធរាល់ពេលឆ្លើយ គឺមិនបានប្រព្រឹត្ត ហើយថា ខ្លួនបានជួបឈ្មោះ [redacted] សុផាត ក៏ដោយ តែមិនបានប្រព្រឹត្តទេ។ ដូច្នេះ សុំឱ្យក្រុមប្រឹក្សាសម្រេច និងពិចារណាលើមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ ការលួចមានគូកន ទោះបីពុំមានការប្រើអំពើហិង្សាក៏ដោយ ក៏ការលួចនេះមានគ្នាច្រើន។

**សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ**

កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ នៅចំណុចផ្ទះលេខ ៦៧E₀ ពិតជាមានអំពើប្លន់កើតឡើងមែន។ កូនក្តីខ្លួនមិនបានទទួលដីកាកោះម្តងណាឡើយ ហើយរាល់ចម្លើយរបស់កូនក្តីខ្លួនឆ្លើយថា ខ្លួនមិនបានចូលរួមធ្វើសកម្មភាពប្លន់ជាមួយឈ្មោះ [redacted] សុផាត ទេ ទើបកូនក្តីខ្លួនប្តឹងឧទ្ធរណ៍សុំឱ្យសាលាឧទ្ធរណ៍ពិនិត្យលើអង្គហេតុទាំងឡាយដែលមាន។ តាមអំណានចម្លើយឈ្មោះ [redacted] សុផាត ឆ្លើយថា កូនក្តីខ្លួនមានដៃកអក្សរ T ហើយកូនក្តីខ្លួនបានឆ្លើយនៅពេលនេះថា បានជួបឈ្មោះ [redacted] សុផាត ដោយចៃដន្យ គឺនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ហើយពេលជិះម៉ូតូជាមួយឈ្មោះ [redacted] សុផាត គាត់បានសួរកូនក្តីខ្លួនថា មានអត្តសញ្ញាណប័ណ្ណទេ ដើម្បីយកម៉ូតូទៅបញ្ចាំ តែកូនក្តីខ្លួនមិនមាន ទើបឈ្មោះនេះទៅរកគ្នាពីរនាក់ទៀត ដើម្បីរកអត្តសញ្ញាណប័ណ្ណយកម៉ូតូទៅបញ្ចាំ។ រឿងនេះមិនអាចចោទថា កូនក្តីខ្លួនចូលរួមទេ ព្រោះកូនក្តីខ្លួនមិនបានទៅចូលរួមបញ្ចាំទេ។ ឈ្មោះ [redacted] ចាន់ពៅ បានទៅតាមដើម្បីរកអត្តសញ្ញាណប័ណ្ណប៉ុណ្ណោះ។ ការបាត់ម៉ូតូនៅ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៨ ហើយកូនក្តីខ្លួនបានជួបឈ្មោះ [redacted] សុផាត នៅថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៨ ចំពោះម៉ូតូ ដែលឈ្មោះ [redacted] សុផាត លួចនោះត្រូវបានតុលាការរឹបអូសនិងបានប្រគល់ទៅឱ្យម្ចាស់ដើមវិញហើយ។ ពុំមានភស្តុតាង ដែលបញ្ជាក់ថា កូនក្តីខ្លួនបានចូលរួមប្រព្រឹត្តជាមួយឈ្មោះ [redacted] សុផាត ខ្លួនពិនិត្យថា កូនក្តីខ្លួនមានកំហុសតិចតួច ដែលបានជិះម៉ូតូជាមួយឈ្មោះ [redacted] សុផាត ប៉ុណ្ណោះ។ សំណូមពរសុំឱ្យក្រុមប្រឹក្សាមេត្តាកែប្រែបទចោទពីមាត្រា ៦ ទៅ មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងសុំបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ដោយអនុគ្រោះ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] វិណ្ណារិទ្ធ ជាជនជាប់ចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទបានឆ្លើយថា នៅថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៨ នោះខ្លួនពុំបានចូលរួមធ្វើសកម្មភាពលួចម៉ូតូគេជាមួយជនជាប់ចោទឈ្មោះ [redacted] **សុផាត**។ ប៉ុន្តែតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុផាត** បានឆ្លើយថា កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៨ ឈ្មោះ [redacted] **វិណ្ណារិទ្ធ** បានបបួលខ្លួនដើរលួចម៉ូតូ ដោយឈ្មោះនេះមានដែករាងអក្សរ T ជាប្រដាប់សម្រាប់កាច់សោរម៉ូតូ។ ពេលលួច គឺជនជាប់ចោទឈ្មោះ **វិណ្ណារិទ្ធ** ជាអ្នកយកដែកនោះទៅចាក់បំបែកគ្រាប់សោរ ម៉ូតូ រួចខ្លួនជាអ្នកជួយរុញបញ្ឆេះ។

ដូច្នេះ ការឆ្លើយបដិសេធរបស់ជនជាប់ចោទមិនមែនជាការបង្ហាញការពិតឡើយ ។

៣- មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ លួចដោយហិង្សា ប្រព្រឹត្តនៅផ្ទះលេខ ៦៧ ផ្លូវថភ្លើង ក្រុម ២៣ ភូមិ ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៨ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះ ដោយអនុលោមតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌ គួរកែប្រែបទចោទ ពីបទ **ប្លន់** តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទ **លួចដោយហិង្សា** តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ វិញ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ៣៧ កប៤ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី ១ ខ គួរកែប្រែ ហើយសម្រេចឡើងវិញដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] **វិណ្ណារិទ្ធ** ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៧ កប៤ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ របស់សាលាដំបូង រាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី ១ ខ ត្រូវកែប្រែបទចោទ ហើយសម្រេចឡើងវិញ:

ក- កែប្រែបទចោទ ពីបទ ប្លន់ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទលួចដោយហិង្សា តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ខ- ផ្តន្ទាទោសឈ្មោះ [redacted] វណ្ណារិទ្ធ ភេទប្រុស ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ (បីឆ្នាំ) គិតពីថ្ងៃ ឃុំខ្លួន ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១១ ពីបទ លួចដោយហិង្សា ប្រព្រឹត្តនៅផ្ទះលេខ ៦៧ ផ្លូវរថភ្លើង ក្រុម ២៣ ភូមិ ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៨ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៧ និងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ។ ក្រៅពីនេះទុកនៅដដែល។

៣- បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១២ ប្រកាសជាសាធារណៈ នៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខតាមច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 12 ខែ 6 ឆ្នាំ ២០១៤
ក្រឡាបញ្ជី